ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០១ ផក

# ផែនការ

# ស្តីពី

# យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣

# រយៈពេល ០១ឆ្នាំ (ចាប់ពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨)

ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនទាំង ២លើក (រយៈពេល ១ឆ្នាំ) របស់រាជរដ្ឋាភិបាល ត្រូវបានចាត់តាំងអនុវត្តយ៉ាងសកម្មផុលផុស ដោយមានការចូលរួមយ៉ាងសស្រាក់សស្រាំពីគ្រប់ស្រទាប់ប្រជាពលរដ្ឋ មន្ត្រីរាជការនិងមហាជនក្នុងសង្គម ដែលបង្កើតបានជាចលនាជាតិក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយទទួលបានលទ្ធផលល្អប្រសើរ ព្រមទាំងមានការគាំទ្រនិងវាយតម្លៃជាវិជ្ជមាន ពីសំណាក់សាធារណៈមតិជាតិ-អន្តរជាតិ ចំពោះស្មារតីទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាល លើជោគវាសនាប្រទេសជាតិ និងប្រជាពលរដ្ឋ។

ជាក់ស្តែង ការអនុវត្តន៍នូវគោលការណ៍ និងវិធានការនៃផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ទាំង ២លើក បានដំណើរការយ៉ាងសកម្ម ជាពិសេសការអនុវត្តនីតិវិធានការច្បាប់ទទួលបានលទ្ធផលខ្ពស់ ដោយសមត្ថកិច្ចពាក់ព័ន្ធបានបើកប្រតិបត្តិការយ៉ាងក្តៅគគុក បង្ក្រាបការជួញដូរ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ចំនួន ៨.១៧៣ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៧.៨០០នាក់ និងសារធាតុញៀនចាប់យកគ្រប់ប្រភេទសរុប ១៨០,២៣៨គ.ក្រ រួមទាំងមធ្យោបាយ សម្ភារៈ វត្ថុតាងមួយចំនួន។ ក្នុងនោះ សមត្ថកិច្ចបានបង្ក្រាបចាប់ខ្លួនមេក្លោងជួញដូរគ្រឿងញៀនធំៗ ចំនួន ៣៤ករណី ព្រមទាំងកាត់ផ្តាច់ខ្សែរយៈបណ្តាញ ធ្វើឲ្យចរន្តនៃការចរាចរ ជួញដូរគ្រឿងញៀនខុសច្បាប់ ថមថយសកម្មភាព។

លទ្ធផលនៃការបង្ក្រាបខាងលើនេះ បានធ្វើឲ្យបទល្មើសព្រហ្មទណ្ឌមានការថយចុះ និងជះឥទ្ធិពលជាវិជ្ជមានដល់បរិយាកាសសន្តិសុខ សណ្តាប់ធ្នាប់ជាទូទៅបម្រើឲ្យយុទ្ធនាការឃោសនា និងបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់នាពេលកន្លងទៅផងដែរ។ ទន្ទឹមនេះ ការបង្ក្រាបឃាត់ខ្លួនជនសង្ស័យពាក់ព័ន្ធបទល្មើសគ្រឿងញៀន និងអ្នកប្រើប្រាស់គ្រឿងញៀនប្រមាណជាង ១៧.៨០០នាក់ បានធ្វើឲ្យស្ថានភាពសន្តិសុខ សណ្តាប់ធ្នាប់ទូទៅនៅមូលដ្ឋានភូមិ-ឃុំ កាន់តែល្អប្រសើរជាងមុន ព្រមទាំងបានជួយស្រោចស្រង់អនាគតយុវវ័យឲ្យរួចផុតពី រណ្តៅគ្រោះថ្នាក់ដោយសារគ្រឿងញៀន និងបានជួយដោះស្រាយទុក្ខលំបាក ក្តីបារម្ភរបស់ពលរដ្ឋក្នុងមូលដ្ឋាន ក៏ដូចជាអាណាព្យាបាល ឬក្រុមគ្រួសាររបស់ពួកគេទៀតផង។

ក៏ប៉ុន្តែអាស្រ័យដោយនិន្នាការនៃការផលិត ការចរាចរ និងការជួញដូរគ្រឿងញៀនខុសច្បាប់នៅក្នុងតំបន់ និងលើពិភពលោក នៅតែមានកំណើន និងនៅតែបន្តជះឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ដល់កម្ពុជា រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ រយៈពេល ០១ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី ០១ ខែ មករា រហូតដល់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨ ដូចខាងក្រោម ៖

## I. គោលគោលការណ៍រួម

- បន្តចាត់តាំងអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាព នូវបទបញ្ជាលេខ ០១ ប.ប ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ចាត់តាំងអនុវត្តយុទ្ធនាការលើកទី៣ ដោយផ្អែកតាមគោលការណ៍រួម និងវិធានការទាំង៥ នៃផែនការ ដែលបានចាត់តាំងអនុវត្តក្នុងយុទ្ធនាការលើកទី១ និងលើកទី២

- បន្តពង្រឹងយន្តការដែលមានស្រាប់ ក្នុងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ និងលើកទី២ ដើម្បីប្រើប្រាស់ជាយន្តការសម្រាប់អនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣។

## II. វិធានការ

បន្តជម្រុញការអនុវត្តន៍វិធានការទាំង ៥ ដែលមានចែងក្នុងផែនការយុទ្ធនាការលើកទី១ និងលើកទី២ ឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ទន្ទឹមនឹងនោះត្រូវធ្វើឲ្យបានសម្រេចនូវការងារសេសសល់ និងត្រូវប្រមូលផ្តុំយកចិត្តទុកដាក់លើការងារចម្បងៗ ជាអាទិភាពដូចតទៅ ៖

១.ត្រូវខិតខំបង្កើនសកម្មភាពអនុវត្តវិធានការផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋទូទៅ ពិសេសត្រូវយកចិត្តទុកដាក់ផ្តោតការអប់រំឲ្យចំគោលដៅ និងមុខសញ្ញាងាយរងគ្រោះ ឲ្យយល់ដឹងកាន់តែទូលំទូលាយ និងស៊ីជម្រៅអំពីគ្រោះថ្នាក់ និងផលអវិជ្ជមានដែលបណ្តាលមកពីគ្រឿងញៀន ព្រមទាំងអំពាវនាវឲ្យចូលរួមក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ សំដៅកាត់បន្ថយបទល្មើសគ្រឿងញៀន និងការពារសុខុមាលភាពសង្គម។

២.ជំរុញសកម្មភាពរៀបចំវេទិកាជួបជាមួយវិស័យឯកជន និងសប្បុរសជន ជាពិសេសម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មដែលអាចងាយកើតមានបទល្មើសគ្រឿងញៀន និងសិល្បករ-សិល្បការិនី បណ្តាញសារព័ត៌មាន អ្នកដឹកនាំសាសនា ព្រមទាំងអង្គការ សង្គមស៊ីវិល ឲ្យបានគ្រប់រាជធានី-ខេត្ត រហូតដល់មូលដ្ឋាន សំដៅប្រមូលផ្តុំឲ្យមានការចូលរួមសហការគាំទ្រទាំងសកម្មភាព និងមូលនិធិ ក្នុងចលនាជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

៣.ពង្រឹងការអនុវត្តន៍វិធានការរដ្ឋបាល និងវិធានការច្បាប់ឲ្យបានហ្មត់ចត់ សំដៅកាត់បន្ថយទីផ្សារជួញដូរ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ដោយត្រូវយកចិត្តទុកដាក់ចំពោះគោលដៅដែលងាយបង្ក ឬកើតមានការជួញដូរ-ប្រើប្រាស់គ្រឿងញៀន។ ពិសេសកំណត់ភូមិសាស្ត្រ និងគោលដៅអាទិភាពជាក់លាក់ ព្រមទាំងមានកម្មវិធីការងារសម្រាប់អនុវត្តកិច្ចការនេះច្បាស់លាស់ជាប្រចាំ។

៤.ជម្រុញការរិះរកនីតិវិធីក្នុងការចាត់ចែងវត្ថុតាង និងទ្រព្យសម្បត្តិនានា ដែលត្រូវបានរឹបអូស និងបង្កកពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនឲ្យបានឆាប់រហ័ស ដើម្បីយកមកគាំទ្រក្នុងសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀន។

៥.ជម្រុញកិច្ចសហប្រតិបត្តិការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន ជាពិសេសបន្តខិតខំទប់ស្កាត់ការនាំចូលពីក្រៅប្រទេស និងស្រាវជ្រាវបង្ក្រាបឲ្យបាននូវបណ្តាញខ្សែរយៈឧក្រិដ្ឋជនជួញដូរគ្រឿងញៀនធំៗ ព្រមជាមួយនឹងការយកចិត្តទុកដាក់ក្នុងការថែប៉ិន និងលើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តច្បាប់ លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅធ្វើឲ្យប្រតិបត្តិការបង្ក្រាបគ្រឿងញៀនខុសច្បាប់ កាន់តែមានប្រសិទ្ធភាពខ្ពស់។

៦.បន្តពង្រឹង និងជម្រុញសកម្មភាពអនុវត្តវិធានការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មជាមួយគ្នានេះ ត្រូវខិតខំលើកកម្ពស់សមត្ថភាព គុណភាព និងពង្រីកសេវាបន្សាបព្យាបាលដោយផ្អែកលើសហគមន៍ និងត្រូវជម្រុញការងារសាងសង់មជ្ឈមណ្ឌលស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈថ្នាក់ជាតិ ឲ្យបានរួចរាល់ ព្រមទាំងបន្តកសាងមណ្ឌលបណ្តោះអាសន្នសម្រាប់ព្យាបាល និងស្តារនីតិសម្បទាតាមរាជធានី-ខេត្ត ដែលមានអំណោយផល។

## III.ការចាត់តាំងអនុវត្ត

១.គណៈបញ្ជាការដឹកនាំយុទ្ធនាការលើកទី៣នេះ គឺ៖

- **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធានយុទ្ធនាការ

- ឯកឧត្តម នាយឧត្តមសេនីយ៍ **កែ គីមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអនុប្រធានយុទ្ធនាការ

- លេខាធិការដ្ឋាន គណៈកម្មការចម្រុះទាំង៦ អនុគណៈកម្មការចម្រុះទាំង៣ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តទាំង២៥ ដែលបានរៀបចំ និងដំណើរការនៅក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ និងលើកទី២ ត្រូវបន្តដំណើរការជាយន្តការសម្រាប់ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣

២.ផ្អែកលើផែនការនេះ គណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ គណៈកម្មការចម្រុះទាំង៦ អនុគណៈកម្មការទាំង៣ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តទាំង២៥ ត្រូវកសាងផែនការជាក់ស្តែង សម្រាប់ចូលរួមអនុវត្តតាមតួនាទី ភារកិច្ចរៀងៗខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

៣.ត្រូវមានវិធានការលើកសរសើរ ជូនរង្វាន់សមស្របដល់អង្គភាព និងបុគ្គលដែលមានស្នាដៃក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀន និងមានវិធានការអនុវត្តវិន័យហ្មឹងម៉ាត់ចំពោះមន្ត្រីដែលមានជាប់ពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

ទទួលបានផែនការនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងគណៈអភិបាលរាជធានី-ខេត្តទាំងអស់ ត្រូវចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធខ្ពស់។

ថ្ងៃ ចន្ទ ១២ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**